**វិទ្យាសាស្ត្រ** អំណាចស្នាដៃ

*វ៉ុល១ លេខទី៥ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩*

# ស្វែងយល់ពីសេដ្ឋកិច្ចឌីជីថល

គង់ រតនធីតា*

ការផ្លាស់ប្តូរបែបឌីជីថល បាននិងកំពុងកើតឡើងដំណាលគ្នានឹងបដិវត្តន៍ឧស្សាហកម្មទី៤។ និន្នាការនៅទូទាំងពិភពលោកនាពេលបច្ចុប្បន្ននេះ បានស្វាគមន៍យ៉ាងក្លៀវក្លានូវបដិវត្តន៍ជំនាន់ថ្មី រាប់បញ្ចូលទាំងអ៊ីនធឺណិត ប្រព័ន្ធទិន្នន័យធំ (Big Data) ប្រព័ន្ធ Cloud Computing បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) និងបច្ចេកវិទ្យាឌីជីថលជាច្រើនទៀតនាពេលថ្មីៗនេះ ហើយបានចោទជាចម្ងល់ទាក់ទិននឹងពាក្យថា «*សេដ្ឋកិច្ចឌីជីថល*»។ ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត (Internet of Things) និងបណ្តាញទំនាក់ទំនងជាប្រចាំលើប្រព័ន្ធអ៊ីនធឺណិត (Hyper-connectivity) រវាងមនុស្ស ពាណិជ្ជកម្ម និងទិន្នន័យ បានក្លាយជាផ្នែកមួយដ៏មានសារសំខាន់នៃជីវិតរបស់យើងដែលមិនធ្លាប់មានពីមុនមក។ រាប់ពីការទិញម្ហូបអាហារតាមអនឡាញដល់ការរៀនសូត្រ និងធ្វើការតាមអនឡាញ ការផ្លាស់ប្តូរតាមទម្រង់នៃប្រព័ន្ធឌីជីថលបានវិវត្តទៅជាគុណប្រយោជន៍បន្ថែមថ្មីដល់វិស័យពាណិជ្ជកម្ម ដែលបានជំរុញឲ្យការរស់នៅកាន់តែមានភាពងាយស្រួល។ ក្រុមហ៊ុនបច្ចេកវិទ្យាដូចជា Apple, Huawei, Microsoft និងវេទិកាអនឡាញដ៏មានឥទ្ធិពលជាច្រើនផ្សេងទៀតដូចជា Google, Amazon, Alibaba, Airbnb, Uber និង Facebook ជាដើម គឺជាឧទាហរណ៍នៃការងារវៃឆ្លាត និងភាពជោគជ័យនៃប្រព័ន្ធ និងបរិស្ថានរបស់សេដ្ឋកិច្ចឌីជីថល។ ក្នុងន័យនេះ សំណួរដ៏សំខាន់ដែលគេចោទសួរគឺថា តើអ្វីទៅគឺជាសេដ្ឋកិច្ចឌីជីថល? តើបច្ចេកវិទ្យាឌីជីថលនេះបាន និងកំពុងមានឥទ្ធិពលបែបណាខ្លះមកលើយើង? តើអ្វីទៅជាឥទ្ធិពលពិតប្រាកដដែលកើតចេញពីការរីកដុះដាលយ៉ាងគំហុករបស់ប្រព័ន្ធឌីជីថលនៅសតវត្សរ៍ទី២១នេះ? អ្វីដែលយើងបានដឹងពីសេដ្ឋកិច្ចឌីជីថលគឺភាពមិនអាចប្រកែកបានថា វាជ្រាបចូលស្ទើរតែគ្រប់ជ្រុងនៃជីវិតរស់នៅ និងសង្គមមនុស្ស ដោយរាប់បញ្ចូលទាំងរបៀបរបបធ្វើការតាមបែបឌីជីថល និងរបៀបដែលមនុស្សប្រាស្រ័យទាក់ទងគ្នា។ ប៉ុន្តែមែនទែនទៅ អ្វីដែលយើងពុំបានដឹងឲ្យច្បាស់នោះ គឺថាតើការផ្លាស់ប្តូរដ៏ធំធេងនេះ នឹងកើតឡើងដោយរបៀបណា? អត្ថបទនេះនឹងផ្តល់ការស្វែងយល់ដោយសង្ខេបអំពីសេដ្ឋកិច្ចឌីជីថលជារួម និងដំណើររបស់វានៅក្នុងបរិបទកម្ពុជា។

## តើអ្វីទៅជាសេដ្ឋកិច្ចឌីជីថល?

បដិវត្តន៍ឧស្សាហកម្មទី១ — បានលេចរូបរាងឡើងដោយតាមរយៈការបង្កើតឧស្សាហកម្មដែក និងដែកថែប ព្រមទាំងម៉ាស៊ីនដើរដោយចំហាយទឹក — ហើយបដិវត្តន៍ឧស្សាហកម្មទី២ — ដែលដំណើរការដោយរបកគំហើញថាមពលអគ្គិសនី ប្រព័ន្ធទូរគមនាគមន៍ និងការបង្កើតខ្សែសង្វាក់ផលិតកម្មនៅក្នុងរោងចក្រ បានត្រួសត្រាយផ្លូវសម្រាប់សន្ទុះយ៉ាងខ្លាំងខ្លានៃការរីកចម្រើនផ្នែកផលិតកម្ម។ នៅក្នុងទសវត្សរ៍៦០ បដិវត្តន៍ឧស្សាហកម្មទី៣ ដែលត្រូវបានគេស្គាល់ផងដែរថាជា បដិវត្តន៍ឌីជីថល បានបង្ហាញវត្តមាននៃយុគសម័យព័ត៌មាន រួមមានការអភិវឌ្ឍប្រព័ន្ធអ៊ីនធឺណិត ព័ត៌មានវិទ្យា (IT) ស៊ីមីកុងឌុចទ័រ (Semiconductor) កុំព្យូទ័រភាវូបនីយកម្ម និងបច្ចេកវិទ្យាជាច្រើនទៀត។ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ក្នុងយុគសម័យឌីជីថល បានតម្រង់ទិសដៅឆ្ពោះទៅកាន់

---

*****គង់ រតនធីតា** ជាអ្នកសម្របសម្រួលគម្រោងទទួលបន្ទុកទំនាក់ទំនងសាធារណៈនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

បដិវត្តន៍ឧស្សាហកម្មទី៤ ហើយបានបង្កើតជាមូលដ្ឋានសម្រាប់ការមកដល់នៃបច្ចេកវិទ្យាទំនើបបំផុតសម្រាប់ការធ្វើពាណិជ្ជកម្មក្នុងយុគសម័យថ្មី ដែលគេស្គាល់ជាទូទៅថា «សេដ្ឋកិច្ចឌីជីថល»។

សេដ្ឋកិច្ចឌីជីថល គឺជាទម្រង់នៃសកម្មភាព និងដំណើរការសេដ្ឋកិច្ចដែលចរាចរនៅលើប្រព័ន្ធអ៊ីនធឺណិតដោយមានជំនួយពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលជំរុញឲ្យមានការតភ្ជាប់កាន់តែទូលំទូលាយបំផុត រវាងនិងក្នុងចំណោមមនុស្ស ពាណិជ្ជកម្ម ឧបករណ៍ និងទិន្នន័យ។ ព័ត៌មាន និងចំណេះដឹងត្រូវបានប្រើប្រាស់ដើម្បីពង្រឹង និងពង្រីកសកម្មភាពផលិតកម្ម។ សេដ្ឋកិច្ចឌីជីថល ក៏ត្រូវបានគេហៅថា សេដ្ឋកិច្ចអ៊ីនធឺណិត (Internet Economy) ឬសេដ្ឋកិច្ចថ្មី (New Economy) ឬសេដ្ឋកិច្ចវេបសាយ (Web Economy) ផងដែរ ដោយសារតែពំនឹងផ្អែកយ៉ាងខ្លាំងលើបណ្ដាញភ្ជាប់ទៅនឹងប្រព័ន្ធអ៊ីនធឺណិត។ ពាក្យ «សេដ្ឋកិច្ចឌីជីថល» ត្រូវបានបង្កើតឡើងដំបូងដោយលោក Don Tapscott ក្នុងឆ្នាំ១៩៩៥ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *«សេដ្ឋកិច្ចឌីជីថល៖ ការសន្យា និងគ្រោះថ្នាក់នៅក្នុងយុគសម័យបណ្ដាញនៃភាពវៃឆ្លាត»*។ តែទោះជាយ៉ាងណា និយមន័យរបស់សេដ្ឋកិច្ចឌីជីថលមានភាពទូលំទូលាយ និងមិនជាក់លាក់ដែលមិនត្រូវបានកំណត់ដោយសកម្មភាព និងដំណើរការតែមួយនោះឡើយ។ ដោយសារបែបនេះហើយ ទើបមានការយល់ឃើញផ្សេងៗគ្នាអំពីថា អ្វីទៅជាសេដ្ឋកិច្ចឌីជីថល។ ខាងក្រោមនេះ គឺជានិយមន័យសេដ្ឋកិច្ចឌីជីថលដែលត្រូវបានកំណត់ដោយអង្គការធំៗនៅលើពិភពលោក។

## ទស្សនទាននានាអំពីសេដ្ឋកិច្ចឌីជីថល

Australian Government

"បណ្ដាញនៃសកម្មភាពសេដ្ឋកិច្ច និងសង្គមជាសកល ដែលត្រូវបានដំណើរការដោយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដូចជាអ៊ីនធឺណិត ទូរស័ព្ទចល័ត និងប្រព័ន្ធ Sensor ជាដើម។"

ADB

"សកម្មភាពសេដ្ឋកិច្ចដែលប្រើប្រាស់លើព័ត៌មាន និងចំណេះដឹងឌីជីថល ជាកត្តាគន្លឹះនៃផលិតកម្មផ្អែកលើអ៊ីនធឺណិត ប្រព័ន្ធ Cloud Computing ទិន្នន័យធំ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីប្រមូល រក្សាទុក វិភាគ និងចែករំលែកព័ត៌មានឌីជីថល និងផ្លាស់ប្ដូរអន្តរកម្មសង្គម។"

OECD

"ទីផ្សារមួយមានមូលដ្ឋានលើបច្ចេកវិទ្យាឌីជីថល ដែលជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៃទំនិញ និងសេវាកម្មតាម រយៈពាណិជ្ជកម្មអេឡិចត្រូនិក។"

UNCTAD

"ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្អែកលើអ៊ីនធឺណិតសម្រាប់ផលិតកម្ម និងការធ្វើពាណិជ្ជកម្មទំនិញ និងសេវាកម្ម។"

Oxford Dictionaries

"សេដ្ឋកិច្ចដែលដំណើរការជាចម្បងដោយបច្ចេកវិទ្យាឌីជីថល ជាពិសេសប្រតិបត្តិការអេឡិចត្រូនិកដែលត្រូវបានធ្វើឡើងផ្អែកលើប្រព័ន្ធអ៊ីនធឺណិត។"

THE WORLD BANK IBRD • IDA | WORLD BANK GROUP

"ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឌីជីថល។"

## ធាតុស្នូលនៃសេដ្ឋកិច្ចឌីជីថល

ចំណុចស្នូលនៃសេដ្ឋកិច្ចឌីជីថលក្នុងយុគសម័យទំនើប គឺការរួមបញ្ចូលនៃ ១) បច្ចេកវិទ្យារ៉ូបូតទំនើប ឧបករណ៍ដ្រូន (Drones) និងស្វ័យប្រវត្តិកម្មរោងចក្រ; ២) ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត; ៣) ប្រព័ន្ធ Cloud Computing; ៤) ប្រព័ន្ធវិភាគទិន្នន័យធំ; និង ៥) បញ្ញាសិប្បនិម្មិត (AI) (UNCTAD, 2017)។ បច្ចេកវិទ្យាទាំងនេះ គឺជាលក្ខណៈពិសេសនៃគំរូពាណិជ្ជកម្មទំនើបថ្មី ដែលត្រូវបានគេសម្គាល់ខុសពីសេដ្ឋកិច្ចធម្មតា។ លោក Thomas Mesenbourg បានកំណត់សមាសធាតុសំខាន់ចំនួន៣របស់សេដ្ឋកិច្ចឌីជីថល រួមមាន ហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មអេឡិចត្រូនិក (e-business infrastructure) អាជីវកម្មអេឡិចត្រូនិក (e-business) និងពាណិជ្ជកម្មអេឡិចត្រូនិក (e-commerce) (Mesenbourg, 2001) ។

ហេដ្ឋារចនាសម្ព័ន្ធដែលអាចដំណើរការតាមបែបឌីជីថល/អាជីវកម្មអេឡិចត្រូនិក គឺជាគ្រឹះនៃសេដ្ឋកិច្ចឌីជីថលដែលឈរលើមូលដ្ឋាននៃបណ្តាញដែលគ្រប់គ្រង និងសម្របសម្រួលដោយប្រព័ន្ធកុំព្យូទ័រ។ ក្នុងនោះរួមមានសម្ភារូបវន្តមូលដ្ឋាន និងការរៀបចំប្រព័ន្ធ ដើម្បីធ្វើការគាំទ្រដល់ដំណើរការអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយរាប់បញ្ចូលទាំងផ្នែករឹង (Hardware) ផ្នែកទន់ (Software) បរិក្ខារ និងសេវាទូរគមនាគមន៍ រចនាសម្ព័ន្ធ ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត និងសេវាគាំទ្រ។ ម៉្យាងវិញទៀត ពាណិជ្ជកម្មអេឡិចត្រូនិក គឺជាដំណើរការណាមួយនៃការលក់ ឬផ្គត់ផ្គង់ទំនិញរាយតាមអនឡាញ និងប្រតិបត្តិការបែបអេឡិចត្រូនិក តាមរយៈការបញ្ជាទិញ ដឹកជញ្ជូនតាម ឬធ្វើប្រតិបត្តិការតាមប្រព័ន្ធឌីជីថល។ ទាំងនោះរួមមាន៖

- អាជីវកម្ម-ទៅ-អាជីវកម្ម (Business-to-business-B2B)៖ ប្រតិបត្តិការទំនិញ និងសេវាកម្មរវាងអាជីវកម្មមួយទៅកាន់អាជីវកម្មមួយផ្សេងទៀត តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។
- អាជីវកម្ម-ទៅ-អតិថិជន (Business-to-consumer-B2C)៖ ការលក់ទំនិញ និងសេវាកម្មដោយអាជីវកម្មមួយទៅអតិថិជន ឬការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក ដូចជាការទិញ លក់រាយតាមប្រព័ន្ធអ៊ីនធឺណិត ឬមធ្យោបាយ អេឡិចត្រូនិកផ្សេងទៀត។
- អ្នកប្រើប្រាស់-ទៅ-អ្នកប្រើប្រាស់ (Peer-to-peer-P2P)៖ "សេដ្ឋកិច្ចចែករំលែក" ឬពាណិជ្ជកម្មអេឡិចត្រូនិកតាមអនឡាញ (platform-based e-commerce) រួមមានការផ្លាស់ប្តូរទំនិញ និងសេវាកម្មរវាងអ្នកប្រើប្រាស់តាមរយៈកម្មវិធីឌីជីថល។
- អាជីវកម្មអេឡិចត្រូនិក៖ ជាដំណើរការដែលអង្គភាពអាជីវកម្មមួយធ្វើអាជីវកម្មខ្លួនលើបណ្តាញគ្រប់គ្រងសម្របសម្រួលដោយប្រព័ន្ធកុំព្យូទ័រ។ ទោះបីមានភាពស្រដៀងគ្នាទៅនឹងពាណិជ្ជកម្មអេឡិចត្រូនិក វាលើសពីការលក់ និងទិញសេវាកម្ម និងផលិតផលតាមអនឡាញ។ អាជីវកម្មអេឡិចត្រូនិក គ្របដណ្តប់យ៉ាងទូលំទូលាយលើដំណើរការអាជីវកម្ម ដូចជាការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ ការលក់និងទីផ្សារ ការគ្រប់គ្រងទំនាក់ទំនងអតិថិជន និងការរៀបចំផែនការធនធានសហគ្រាសជាដើម។

លើសពីនេះ Barefoot et al., (2018) បានរៀបរាប់ស្រដៀងគ្នានេះដែរ ប៉ុន្តែបានបន្ថែមសមាសធាតុមួយទៀត គឺប្រព័ន្ធផ្សព្វផ្សាយឌីជីថល ជាធាតុផ្សំសំខាន់នៃសេដ្ឋកិច្ចឌីជីថល។ ប្រព័ន្ធផ្សព្វផ្សាយឌីជីថល គឺជាខ្លឹមសារដែលមនុស្សបង្កើតឡើង បើកឲ្យមានការចូលមកយករក្សាទុក ឬមើលតាមឧបករណ៍ឌីជីថល រួមមានប្រព័ន្ធផ្សព្វផ្សាយឌីជីថលលើការលក់ដោយផ្ទាល់ (ផលិតផលឌីជីថលត្រូវបានលក់ដោយផ្ទាល់ទៅអ្នកប្រើប្រាស់ក្នុងតម្លៃមួយ); ប្រព័ន្ធផ្សព្វផ្សាយឌីជីថលឥតគិតថ្លៃ (ប្រាក់ចំណូលទទួលបានពីការផ្សាយពាណិជ្ជកម្មនៃផលិតផលឌីជីថល); និង ទិន្នន័យធំ (ជាយន្តការសម្រាប់ប្រមូលព័ត៌មានអំពីឥរិយាបថ និងចំណូលចិត្តអ្នកប្រើប្រាស់) ។

## ឥទ្ធិពលរបស់សេដ្ឋកិច្ចឌីជីថល

វត្តមានរបស់បច្ចេកវិទ្យាទំនើបចុងក្រោយបង្អស់ដូចជាប្រព័ន្ធ Cloud Computing បច្ចេកវិទ្យា Augmented និង Virtual reality ការបោះពុម្ព 3D ការប្រាស្រ័យទាក់ទងពីម៉ាស៊ីនមួយទៅម៉ាស៊ីនមួយ បច្ចេកវិទ្យា Sensor ខ្សែសង្វាក់ផលិតកម្ម ទិន្នន័យធំ ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត បញ្ញាសិប្បនិម្មិត ប្រព័ន្ធ 5G និងបច្ចេក

វិទ្យាចែកចាយទិន្នន័យ (Distributed Ledger Technologies) ជាដើម បានបង្ហាញពីតួនាទីរបស់ឌីជីថលូបនីយកម្មក្នុងការជួយជ្រោមជ្រែងបរិស្ថានមួយ ដែលផ្តល់អត្ថប្រយោជន៍ដល់ទាំងសេដ្ឋកិច្ច និងសង្គម។ ការអនុវត្តបច្ចេកវិទ្យាជឿនលឿនទាំងនោះ បានជួយឲ្យដំណើរការផលិតកម្មនាពេលបច្ចុប្បន្ន និងប្រព័ន្ធគ្រប់គ្រងអាជីវកម្ម អាចបង្កើននូវផលចំណេញបានល្អប្រសើរជាមុន និងលឿនជាងអ្វីដែលត្រូវបានផ្តល់ជូនដោយវិធីប្រពៃណីក្នុងប្រតិបត្តិការអាជីវកម្ម។ សេដ្ឋកិច្ចឌីជីថលបានរៀបចំរចនាសម្ព័ន្ធអាជីវកម្មថ្មី ដោយផ្អែកលើប្រព័ន្ធអ៊ីនធឺណិតផ្ទៃក្នុង (intranet) និងប្រព័ន្ធអ៊ីនធឺណិតខាងក្រៅ (internet) ដែលជំរុញឲ្យមានសមិទ្ធផល និងប្រសិទ្ធផលខ្ពស់។ អ្វីដែលសំខាន់ជាងនេះទៀតនោះ គឺដំណើរការអន្តរកម្ម និងការចូលរួមកាន់តែច្រើនរវាងអ្នកលក់ និងអ្នកប្រើប្រាស់ ដែលធ្វើឲ្យអតិថិជនទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជា តម្លាភាព តម្លៃ ជម្រើស ការវាយតម្លៃ និងភាពងាយស្រួល។ ដោយសារការទាមទារឲ្យមានការប្រើប្រាស់គំនិត និងជំនាញខ្ពស់ សេដ្ឋកិច្ចឌីជីថលដើរតួយ៉ាងសំខាន់ក្នុងការពង្រឹង និងពង្រីកសកម្មភាពឧស្សាហកម្ម និងជំរុញផលិតភាព និងភាពប្រកួតប្រជែងឲ្យកាន់តែធំឡើង។ ក្រៅពីនេះ សេដ្ឋកិច្ចឌីជីថលក៏រួមចំណែកដល់នវានុវត្តន៍ ព្រមទាំងការបង្កើតសេវាកម្ម និងការងារថ្មីសម្រាប់ប្រជាជនដែលមានសមត្ថភាព និងទេពកោសល្យ ហើយអាចសម្របខ្លួនទៅនឹងវាបាន។

វលោកនៃការផ្លាស់ប្តូរបែបឌីជីថលនេះក៏បាន និងកំពុងផ្លាស់ប្តូរ និងជះឥទ្ធិពលយ៉ាងខ្លាំងលើវឌ្ឍនភាព និងដំណើរជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ក្នុងការបង្កើតនូវសង្គមឌីជីថលដែលគេរំពឹងទុកថានឹងជាបរិស្ថានមួយកាន់តែមានបរិយាបន្ន និរន្តរភាព សុវត្ថិភាព និងនវានុវត្តន៍បន្ថែមទៀត តាមរយៈការកាត់បន្ថយ និងដោះស្រាយបញ្ហាសង្គមនានា ដូចជាវិសមភាពនៃការបែងចែកផលប្រយោជន៍សេដ្ឋកិច្ចដែលមានពីមុន។ ដើម្បីដោះស្រាយវិសមភាព និងកង្វះនៃបរិយាបន្ននៃការអភិវឌ្ឍ ឌីជីថលូបនីយកម្មមានសក្តានុពលក្នុងការបង្កើនវិសាលភាពទូលំទូលាយឲ្យបានទៅដល់ ក្រុមដែលពុំទទួលបានឱកាសនៅក្នុងទីផ្សារតាមរយៈការបញ្ចុះតម្លៃប្រតិបត្តិការ និងកាត់បន្ថយវិសមភាពនៃការទទួលបានព័ត៌មាន។ ការរីកដាលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលនាំមកដោយឌីជីថលូបនីយកម្ម អាចផ្តល់ភាពអង់អាចដល់បុគ្គល និងក្រុមហ៊ុននានា ហើយសម្រួលបរិយាកាសរស់នៅឲ្យកាន់តែប្រសើរ តាមរយៈការបង្កើនលទ្ធភាពទទួលបានឱកាសនៃការធ្វើពាណិជ្ជកម្មដោយសេរី និងយុត្តិធម៌ ការដឹកជញ្ជូន និងភ័ស្តុភារ សេវាហិរញ្ញវត្ថុ កម្មន្តសាល និងកសិកម្ម ការអប់រំ សេវាសុខាភិបាល និងប្រព័ន្ធផ្សព្វផ្សាយជាដើម។ សេដ្ឋកិច្ចឌីជីថល បាននាំមកនូវអត្តសញ្ញាណឌីជីថល ដែលគេជឿជាក់ថា នឹងត្រួសត្រាយផ្លូវសម្រាប់អនាគតឌីជីថលប្រកបដោយសុវត្ថិភាព និងភាពធន់ជាងមុនសម្រាប់គ្រប់ទិដ្ឋភាពនៃជីវិត។

ដោយគួរឲ្យកត់សម្គាល់ ខណៈពេលដែលឌីជីថលូបនីយកម្មបាននាំយកមកនូវអត្ថប្រយោជន៍ប្រកបដោយសក្តានុពលជាច្រើន ដល់សេដ្ឋកិច្ច និងសង្គម វាក៏បានបង្កឲ្យមានការព្រួយបារម្ភមួយចំនួនដូចគ្នា។ ទោះបីជាមានការកើនឡើងនៃនិន្នាការឌីជីថលូបនីយកម្មក្តី ការបែងចែកឌីជីថលនៅតែជាបញ្ហាប្រឈម ដោយសារការចែកចាយមិនស្មើភាពគ្នានៃការទទួលបាន ការប្រើប្រាស់ និងផលប៉ះពាល់នៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងចំណោមប្រជាជន។ ឧទាហរណ៍ ជំនួសឲ្យការប្រើប្រាស់បច្ចេកវិទ្យាដ៏កាន់តែទូលំទូលាយ បញ្ហាដូចជាការចំណាយខ្ពស់ក្នុងការទិញទូរស័ព្ទស្មាតហ្វូន និងលទ្ធភាពក្នុងការទទួលបានអ៊ីនធឺណិតប្រើប្រាស់នៅតែនៅឆ្ងាយពីបុគ្គលមួយចំនួនធំនៅឡើយ ដែលជាកត្តារាំងស្ទះដល់ការទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចឌីជីថលដោយស្មើភាពគ្នា។ នៅពេលដែលបច្ចេកវិទ្យាឌីជីថលត្រូវបានទទួលយកទាំងស្រុង វានឹងទាមទារឲ្យមានជាចាំបាច់នូវជំនាញឌីជីថល ហើយដំណើរការឌីជីថលនឹងធ្វើឲ្យរំខានដល់ទីផ្សារការងារ និងផ្លាស់ប្តូរសមាសភាពការងារដែលមានស្រាប់។ មិនត្រឹមតែប៉ុណ្ណោះ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីពង្រឹងកម្រិតហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្រ្ត ដើម្បីទទួលបាន និងចាប់យកអត្ថប្រយោជន៍ឌីជីថលជាអតិបរមា។




*ប្រភព៖ វេទិកាសេដ្ឋកិច្ចពិភពលោក*

## តើកម្ពុជានាពេលបច្ចុប្បន្នស្ថិតក្នុងចំណុចណានៃសេដ្ឋកិច្ចឌីជីថល?

ជាមួយនឹងការរីកលូតលាស់នៃបដិវត្តន៍ឧស្សាហកម្មទី៤ ការផ្លាស់ប្តូរបែបឌីជីថល នឹងក្លាយជាគំរូថ្មីនៃក្បាលម៉ាស៊ីនសម្រាប់កំណើនសេដ្ឋកិច្ចដ៏សំខាន់បំផុតមួយដែលមិនអាចចៀសបាន ប្រសិនបើកម្ពុជាត្រូវការសម្រេចចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ក្នុងការក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ក្នុងការកសាងមូលដ្ឋានដើម្បីសម្រេចនូវក្តីស្រមៃនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសផែនការដើម្បីប្រែក្លាយកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថលត្រឹមឆ្នាំ២០២៣។ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា៖

> *សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជា បច្ចេកវិទ្យាថ្មីផ្តល់នូវឱកាសក្នុងការលោតផ្លោះដំណាក់កាលបែបប្រពៃណីនៃការអភិវឌ្ឍ... វាត្រូវការរយៈពេលយ៉ាងតិច១០ឆ្នាំ ដើម្បីផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចឌីជីថលពេញលេញមួយ (ខែឧសភា ២០១៩)។*

អ្វីដែលសំខាន់បំផុតគឺ ដើម្បីត្រៀមសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤ រាជរដ្ឋាភិបាលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ អំពីខ្លឹមសារស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ចក្នុងចតុកោណទី២។ ការត្រៀមខ្លួនរួចរាល់សម្រាប់ឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល និងឧស្សាហកម្ម៤.០ ក៏ត្រូវបានទទួលស្គាល់ក្នុងមុំទី៣ នៃយុទ្ធសាស្ត្រដែលបានចែង។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ពីសារសំខាន់នៃសេដ្ឋកិច្ចឌីជីថល ថាជាកម្លាំងស្នូលក្នុងរុញច្រានកំណើនសេដ្ឋកិច្ច ដែលជាលទ្ធផលនឹងបង្កើតឲ្យមានការងារ និងអាជីវកម្មថ្មីៗកាន់តែច្រើនឡើង ហើយទាំងនេះសុទ្ធសឹងតែជាឱកាសល្អបំផុតសម្រាប់កម្ពុជាក្នុងការកែលម្អរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន (យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ២០១៨)។ ដោយឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត និងដាក់ឲ្យ

ប្រើប្រាស់នូវក្របខណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈពេលវែង និងគោលនយោបាយពាក់ព័ន្ធមួយចំនួនផ្សេងទៀត ដូចជា គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ច្បាប់ស្តីពីទូរគមនាគមន៍ និងក្របខណ្ឌយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរយៈពេលវែង។ លើសពីនេះ ក្របខណ្ឌគតិយុត្តនានាដូចជារដ្ឋាភិបាលឌីជីថល និងយុទ្ធសាស្ត្រសន្តិសុខព័ត៌មាន ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក និងច្បាប់ស្តីពីសន្តិសុខតាមអ៊ីនធឺណិតត្រូវបានផ្សព្វផ្សាយដើម្បីជួយដល់ប្រព័ន្ធបរិស្ថានឌីជីថល ក៏ដូចជាគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលជារួមផងដែរ។

នៅកម្ពុជា សេវាកម្មតាមតម្រូវការដូចជា BookMeBus, PassApp និងNham24 ជាដើម បាន និងកំពុងស្ថិតក្នុងចំណោមសេវាកម្មបច្ចេកវិទ្យាដែលមានឥទ្ធិពលបំផុតនាពេលថ្មីៗនេះ ដែលផ្តល់ជូននូវសេវាកម្មតាមតម្រូវការជាច្រើន រាប់ចាប់ពីការដឹកជញ្ជូនដល់ការចែកចាយអាហារ និងសេវាកម្មផ្សេងទៀតដែលប្រជាជនកម្ពុជាត្រូវការ។ ក្រៅពីនេះបច្ចេកវិទ្យាហិរញ្ញវត្ថុដែលហៅថា ហ្វីនតិចក៏បានដើរតួនាទីដ៏សំខាន់ដូចគ្នា ក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរយៈពេលមួយដ៏ខ្លីប៉ុណ្ណោះ។ ជាក់ស្តែង កម្មវិធីធនាគារចល័តរបស់ធនាគារ ABA និង PiPay គឺជាឧទាហរណ៍បង្ហាញយ៉ាងជាក់លាក់ពីឥទ្ធិពលនៃសេវាកម្មទូទាត់តាមអ៊ីនធឺណិតក្នុងការលើកកម្ពស់បរិយាកាសនៃការចំណាយមិនត្រូវការសាច់ប្រាក់នៅកម្ពុជា។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបង្ហាញខ្លួនមកជំនួសរបៀបនៃការដើរទិញឥវ៉ាន់តាមបែបប្រពៃណីនៅក្នុងទីផ្សារជាក់ស្តែង។ ចំនួនហាងលក់តាមអនឡាញបន្តពង្រីកខ្លួនទៅតាមការផ្គត់ផ្គង់ប្រភេទផលិតផលផ្សេងៗចាប់ពីអាហារភេសជ្ជៈ រហូតដល់សម្លៀកបំពាក់ និងគ្រឿងបន្លាស់នានា តាមរយៈប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម ជាពិសេសហ្វេសប៊ុក និងអ៊ីនស្តាក្រាមក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ និន្នាការដែលកំពុងរីកលូតលាស់ទាំងនេះ បានបង្ហាញពីរបៀបដែលឌីជីថលធ្វើឲ្យប៉ះពាល់ដល់ឥរិយាបថរបស់អ្នកប្រើប្រាស់កម្ពុជានិងរបៀបរស់នៅរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកឌីជីថលក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសរវាងមនុស្សវ័យចំណាស់ និងយុវជនជំនាន់ក្រោយនៅតែបន្តជាបញ្ហាប្រឈមដែលធ្វើឲ្យរដ្ឋាភិបាលពិបាកក្នុងការធ្វើយ៉ាងណា ដើម្បីឲ្យមនុស្សម្នាក់ៗ ទទួលបានសមភាពនៃការចែកចាយយ៉ាងពេញលេញ។ ដូច្នេះ វាជារឿងចាំបាច់ណាស់ក្នុងការដោះស្រាយបញ្ហាបែបនេះ ដោយធានាថាមនុស្សគ្រប់គ្នាអាចមានលទ្ធភាពទទួលបានសមភាពនៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងប្រព័ន្ធអ៊ីនធឺណិត។ អ្វីដែលសំខាន់ជាងនេះ និងជាផ្នែកមួយនៃការទាញយកប្រយោជន៍ជាអតិបរមាពីការផ្លាស់ប្តូរបែបឌីជីថលនោះ គឺការយកចិត្តទុកដាក់ជំរុញនូវអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (Media Literacy) តាមរយៈការបង្កើត និងអភិវឌ្ឍកម្មវិធីអប់រំ និងបណ្តុះបណ្តាល ដែលផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឲ្យបានទូលំទូលាយ ដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជន។ ការធ្វើដូច្នេះ នឹងមិនត្រឹមតែជួយជំរុញឲ្យមានបរិស្ថានឌីជីថលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឲ្យមនុស្សនូវជំនាញថ្មីដែលត្រូវការជាចាំបាច់សម្រាប់យុគសម័យបច្ចេកវិទ្យាទំនើប និងបដិវត្តន៍ឧស្សាហកម្មទី៤។

## ឯកសារយោង


(2019). *G20 Ministerial Statement on Trade and Digital Economy.* Retrieved from https://g20trade-digital.go.jp/dl/Ministerial_Statement_on_Trade_and_Digital_Economy.pdf

(2018). *Rectangular Strategy Phase IV.* Phnom Penh.

(2018). *World Trade Report .* https://www.wto.org/english/res_e/publications_e/wtr18_2_e.pdf.

ADB. (2018). *Understanding the Digital Economy: What Is It and How Can It Transform Asia?* Retrieved from Asia Development Bank : https://www.adb.org/news/events/understanding-digital-economy-what-it-and-how-can-it-transform-asia

Ahmad, N. (2018). *Towards a Framework for Measuring the Digital Economy.* Paper prepared for the 16th Conference of IAOS, OECD, Paris.

Alina, N. (2016 ). *Trend and Dimension of Digital Economy .* Univeristy of Petrosani .

Australian Government. (n.d.). *The Concept of Digital Economy*. Retrieved from Australian Government: https://www.alrc.gov.au/publications/3-policy-context-inquiry/concept-digital-economy

Barefoot, K., Curtis, D., Jolliff, W., Nicholson, J. R., & Omohundro, R. (2018). *Defining and Measuring the Digital Economy.* Working Paper, U.S. Department of Commerce , Bureau of Economic Analysis , Washington. Retrieved from https://www.bea.gov/sites/default/files/papers/defining-and-measuring-the-digital-economy.pdf

Bukht, R., & Heeks, R. (2017). *Defining, Conceptualising and Measuring the Digital Economy.* Centre for Development Informatics, Global Development Institute, SEED. Retrieved from http://www.gdi.manchester.ac.uk/research/publications/working-papers/di/

Council of the European Union. (2018). *Council Conclusion on Cambodia.* Brussels.

*Electronic Business (E-Business)*. (n.d.). Retrieved from Technopedoa : https://www.techopedia.com/definition/1493/electronic-business-e-business

European Commission. (2013). *Revised EU trade scheme to help developing countries applied on 01 January 2014.* Brussels: European Commission.

European Union. (2012). Regulations (EU) No. 978/2012 of the European Parliament and of the council of 25 october 2012. 10.

Heng, P. (n.d.). *Embracing the Digital Economy: Policy Considerations for Cambodia.* Enrich Institute.

IMF. (2018). *Measuring Digital Economy.* Washington, D.C. : International Monetary Fund.

Manet, S. (2018, March 7). *Cambodia to be a digital economy by 2023*. Retrieved from Khmer Times : https://www.khmertimeskh.com/112147/cambodia-to-be-a-digital-economy-by-2023/

May, K. (2019, 03 13). *Full-fledged digital economy not likely in the next decade: Minister*. Retrieved from Khmer Times: https://www.khmertimeskh.com/50586102/full-fledged-digital-economy-not-likely-in-the-next-decade-minister/

Mesenbourg, T. L. (2001). *Measuring the Digital Economy .* Retrieved from https://www.census.gov/content/dam/Census/library/working-papers/2001/econ/umdigital.pdf

OECD. (2012). *The Digital Economy 2012.*

OECD. (2017). *OECD Digital Economy Outlook 2017.* Paris: OECD Publishing. Retrieved from https://www.oecd-ilibrary.org/science-and-technology/oecd-digital-economy-outlook-2017_9789264276284-en

Oxford, D. (n.d.). *Digital Economy*. Retrieved from Oxford Dictionary: https://en.oxforddictionaries.com/definition/us/digital_economy

Ramos, M., & Steiner, A. (2019, 01 16). *How the digital finance revolution can drive sustainable development*. Retrieved from World Economic Forum: https://www.weforum.org/agenda/2019/01/digital-finance-can-help-sustainable-development-goals

Sirimanne, S. N. (2017). *The Development Dimension of e-Commerce and Digital Economy.* Intergovernmental Group of Experts on e-Commerce and Digital Economy, United Nations Conference on Trade and Development, Geneva. Retrieved from https://unctad.org/meetings/en/Presentation/tdb_ede2017p01_SSirimanne_en.pdf

Smith, J., & Amour, L. S. (2019, Jan 18). *This is the digital future we need*. Retrieved from World Economic Forum: https://www.weforum.org/agenda/2019/01/the-digital-future-we-need

UNCTAD. (2016). *The Least Developed Countries Report 2016: The Path to Graduation and Beyong-Making the Most of the Process.* UNCTAD.

UNCTAD. (2017). *The New Digital Economy and Development.* Retrieved from https://unctad.org/en/PublicationsLibrary/tn_unctad_ict4d08_en.pdf

*What is Digital Economy?* (2017, June 28). Retrieved from Youtube : https://www.youtube.com/watch?v=kQPs__9WT9k

WTO. (2018). *The Future of World Trade: How digital economies are transforming global commerce?* World Trade Report 2018, WTO. Retrieved from https://www.wto.org/english/res_e/publications_e/world_trade_report18_e.pdf

Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center